**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**
លេខ : ១០២/០០២/២០០៦
ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៦

**សេចក្តីសម្រេច**
លេខ : ០៧៤/០០១/២០០៦ កបធ.ច
ចុះថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០០៦

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៦/០០៦ ចុះថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០០៦ ប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ៨២ មាត្រា ៨៨ថ្មី មាត្រា ៩០ថ្មី មាត្រា ៩៨ មាត្រា ១០៦ថ្មី មាត្រា ១១១ថ្មី (មួយ) មាត្រា ១១៤ថ្មី នៃរដ្ឋធម្មនុញ្ញ និងមាត្រា ៦ នៃច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញលិខិតលេខ ២០/២០០៣ កបធ ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០០៣ របស់ក្រុមប្រឹក្សាធម្មនុញ្ញ ដែលទូលថ្វាយយោបល់ចំពោះព្រះមហាក្សត្រអំពីចំណុចផ្នែកច្បាប់មួយចំនួន ពិសេសអំពីព្រះរាជតំណាង ដែលមានចែងក្នុងប្រការ ៥ថ្មី(ពីរ) នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញលិខិតលេខ ២៧៤ រស ចុះថ្ងៃទី ១៥ ខែ មីនា ឆ្នាំ២០០៦ របស់សម្តេច **ហេង សំរិន** អនុប្រធានទី១ រដ្ឋសភា ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពលើវិសោធនកម្មប្រការ ២ ថ្មី ៥ ថ្មី ១០ ថ្មី ៣៥ ៤៧ ថ្មី(ពីរ) និង ប្រការ ៨២ នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ដែលអគ្គ-លេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី ១៥ ខែមីនា ឆ្នាំ២០០៦ វេលាម៉ោង ១០:៣១ នាទី។

**ក្រោយពីបានស្តាប់សេចក្តីរាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាស្របតាមច្បាប់ហើយ**

- យល់ឃើញថា មាត្រា ១៤០ថ្មី នៃរដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៩៣ ត្រង់កថាខណ្ឌទី២ ឃ្លាទី ១ ចែងថា " *បទបញ្ជាផ្ទៃក្នុងរដ្ឋសភា បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា និង ច្បាប់រៀបចំអង្គការទាំងឡាយ ត្រូវតែបញ្ជូនទៅក្រុមប្រឹក្សាធម្មនុញ្ញ*

*ពិនិត្យមុននឹងប្រកាសឱ្យប្រើ ។*" និងមាត្រា ១៦ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ បានចែងថា " *ច្បាប់រៀបចំអង្គការ បទបញ្ជាផ្ទៃក្នុងរដ្ឋសភា និង វិសោធនកម្មនៃច្បាប់រៀបចំអង្គការ និង បទបញ្ជាផ្ទៃក្នុងរដ្ឋសភា ក្រោយពីរដ្ឋសភាបានអនុម័តត្រូវដាក់ជូនក្រុមប្រឹក្សាធម្មនុញ្ញ ដោយប្រធានរដ្ឋសភា ដើម្បីពិនិត្យតើច្បាប់ទាំងនោះស្រប ឬ មិនស្របនឹងរដ្ឋធម្មនុញ្ញ មុននឹងត្រូវបានប្រកាសឱ្យប្រើ* " ។

សំណើរបស់សម្តេច **ហេង សំរិន** អនុប្រធានទី១ រដ្ឋសភា លេខ ២៧៤ រស ចុះថ្ងៃទី ១៥ ខែ មីនា ឆ្នាំ២០០៦ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលនៅថ្ងៃទី ១៥ ខែ មីនា ឆ្នាំ២០០៦ វេលាម៉ោង ១០:៣១ នាទី គឺស្របតាមរដ្ឋធម្មនុញ្ញ និង ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ។ ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកសំណើសុំពិនិត្យធម្មនុញ្ញភាពនេះមកពិនិត្យបាន ។

- យល់ឃើញថា វិសោធនកម្មនៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ដែលបានអនុម័តនៅថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី៤ នីតិកាលទី៣ត្រង់ប្រការ ២ថ្មី ៥ថ្មី ១០ថ្មី ៣៥ ៤៧ ថ្មី ( ពីរ ) និង ប្រការ ៨២ ពុំមានលក្ខណៈផ្ទុយនឹងរដ្ឋធម្មនុញ្ញទេ ។

**សម្រេច**

**មាត្រា១.** វិសោធនកម្មប្រការ ២ ថ្មី ៥ ថ្មី ១០ ថ្មី ៣៥ ៤៧ ថ្មី(ពីរ) និងប្រការ ៨២ នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ដែលបានអនុម័តនៅថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី៤ នីតិកាលទី៣ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ ។

**មាត្រា២.** សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ១៧ ខែ មីនា ឆ្នាំ២០០៦ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ២០០៦

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

ប៊ិន ឈិន